ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៩៧៥៧ កសក

# លិខិតអម

**គោរពជូន៖ -ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**-ឯកឧត្តម លោក លោកស្រី ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង**

| ល.រ | រាយមុខលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១ | -របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំនព្វមាស ឆ្នាំ២០២២** និងទិសដៅអនុវត្តបន្ត ........... | ១ច្បាប់ | "ដើម្បីជូនជ្រាប" ---------- |

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ ១៣ ឆ្នាំ២០២២

**ត.ប.រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គលេខាធិការ**

**ស្រី ឌុស្សី**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំនព្វមាស ឆ្នាំ២០២២ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងនព្វមាសនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបាន ២ ៦៩២ ០៩២ហ.ត ស្មើនឹង១០២,៧៧% នៃផែនការចំនួន ២ ៦១៩ ៥០០ហ.ត។ វិធានការជួយសង្គ្រោះបន្ទាន់ និងវិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេស បទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងនព្វមាស ឆ្នាំ២០២២នេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់ ការប្រជុំពិចារណា រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២២ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងនព្វមាស ឆ្នាំ២០២២ នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១- លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៧០០ ៨៥៦ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៩ ៣៦៦ហ.ត ស្មើនឹង០,៣៥% និងដោយគ្រឿងយន្តចំនួន ២ ៦៩១ ៤៩០ហ.ត ស្មើនឹង៩៩,៦៥% តិចជាងឆ្នាំមុន ១៤៩ ៣៨៨ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ១០ ១៣៣ហ.ត តិចជាងឆ្នាំមុន ២ ២៥៩ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៦៩២ ០៩២ហ.ត ស្មើនឹង១០២,៧៧% នៃផែនការចំនួន ២ ៦១៩ ៥០០ហ.ត តិចជាងឆ្នាំមុន ១៣៤ ១៤១ហ.ត។

#### ១.២ ការប្រមូលផលស្រូវស្រាលរដូវវស្សា

ការប្រមូលផលស្រូវស្រាលសម្រេចចំនួន ៥៤១ ៧៨៨ហ.ត ទទួលបរិមាណផលសរុបចំនួន ២ ១៦៣ ២០៨តោន និងទទួលបានទិន្នផលគិតជាមធ្យម ៣,៩៩៣តោន/ហ.ត។

#### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៥១ ៦១៧ហ.ត ស្មើនឹង៨៩,១៥% នៃផែនការចំនួន ៥៧ ៩០០ហ.ត តិចជាងឆ្នាំមុន ៣ ៧៧៩ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៨២៣ ១៩១ហ.ត ស្មើនឹង១០៥,៧៧% នៃផែនការចំនួន ៧៧៨ ៣០០ហ.ត លើសឆ្នាំមុន ៤០ ២២៤ហ.ត។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

## ១.៤ ការនាំចេញផលិតផលកសិកម្ម

### ១.៤.១ ការនាំចេញអង្ករ

បរិមាណការនាំចេញអង្កររយៈពេល៩ខែមានចំនួន ៤៤៩ ៣៦១តោន កើនឡើងចំនួន ៣៨ ៦៦៣តោន (៩,៤១%) បើធៀបបរិមាណនាំចេញរយៈពេល៩ខែឆ្នាំ២០២១ ដែលមានចំនួន ៤១០ ៦៩៨តោន។ ក្នុងនោះខែកញ្ញា ឆ្នាំ២០២២ មានចំនួន ៦០ ៣៦១តោន ថយចុះចំនួន ៦ ៨៩០តោន (-១០,២៥%) បើធៀបខែកញ្ញា ឆ្នាំ២០២១ មានចំនួន ៦៧ ២៥១តោន។

អង្ករក្រអូបគ្រប់ប្រភេទមានចំនួន ៣១០ ៣២២តោន ស្មើនឹង ៦៩,០៦% អង្ករសគ្រប់ប្រភេទមានចំនួន ១២៨ ៣៥៩តោន ស្មើនឹង ២៨,៥៦% និងអង្ករចំហុយគ្រប់ប្រភេទមានចំនួន ១០ ៦៨០តោន ស្មើនឹង ២,៣៨%។

បរិមាណអង្ករនាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២៣ប្រទេស មានបរិមាណសរុបចំនួន ១៥១ ៧១៩តោន (កើនឡើងចំនួន ៤៧ ៤៩៧តោន ស្មើនឹង ៤៥,៥៧%) ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ២០៤ ៩៤២តោន (កើនឡើងចំនួន ១ ៦៦៣តោន ស្មើនឹង ០,៨២%) ទិសដៅអាស៊ានចំនួន ៤ប្រទេស មានបរិមាណសរុបចំនួន ៤០ ៩០៤តោន (ថយចុះចំនួន ៥៧២តោន ស្មើនឹង -១,៣៨%) និងទិសដៅដទៃទៀតចំនួន ២៥ប្រទេស មានបរិមាណសរុប ៥១ ៧៩៦តោន (ថយចុះចំនួន ៩ ៩២៥តោន ស្មើនឹង -១៦,០៨%)។

ក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៥៤ក្រុមហ៊ុន ហើយបរិមាណអង្ករដែលបាននាំចេញដោយក្រុមហ៊ុនធំៗ ចំនួន១០ មានរហូតដល់ ៣០៩ ៦៤៧តោន (៦៨,៩១%) និងក្រុមហ៊ុន ៤៤ដទៃទៀតបាននាំចេញត្រឹមតែ ១៣៩ ៧១៤តោន (៣១,០៩%)។

### ១.៤.២ ការនាំចេញស្រូវ

ក្នុងរយៈពេល៩ខែឆ្នាំ២០២២ ការនាំចេញស្រូវមានចំនួន ២ ៣៥៧ ៦៧១តោន ទៅកាន់ប្រទេសវៀតណាម (មានវិញ្ញាបនបត្រកូតតាមអនាម័យចំនួន ១ ៥៩៧ ៤០០តោន) ថយចុះចំនួន ១៦៥ ៥៩២តោន (-៦,៥៦%) បើធៀបរយៈពេលដូចគ្នានៅឆ្នាំ២០២១ ដែលមានចំនួន ២ ៥២៣ ២៦៣តោន។

### ១.៤.៣ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករ

ក្នុងរយៈពេល៩ខែឆ្នាំ២០២២ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ៤ ៤២៣ ១៦៥,៨៦តោន កើនឡើងចំនួន ៥២៨ ៦៨០,៤៥តោន ស្មើនឹង១៣,៥៨% បើធៀបរយៈពេល៩ខែឆ្នាំ២០២១ ដែលមានចំនួន ៣ ៨៩៤ ៤៨៥,៤១តោន ដែលក្នុងនោះរួមមាន៖

- ចំណិតដំឡូងមីក្រៀមមានចំនួន ១ ៦៣៩ ៨៤០តោន (កើនឡើងចំនួន ២៥,២៨%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ១ ១៧៩ ៣០០តោន និងប្រទេសវៀតណាមចំនួន ៤៦០ ៥៤០តោន
- ដំឡូងមីស្រស់មានចំនួន ១ ០៤៩ ៣០០តោន (កើនឡើងចំនួន ៨២,២០%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៦៣១ ៣៥០តោន និងប្រទេសថៃចំនួន ៤១៧ ៩៥០តោន
- ម្សៅដំឡូងមីមានចំនួន ៥០ ៧៦៣តោន (កើនឡើងចំនួន ១២៦,៦៥%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៤៨ ៨៩៥តោន សហរដ្ឋអាមេរិកចំនួន ៦៦៦តោន ប្រទេសអ៊ីតាលីចំនួន ៥៦៥តោន ប្រទេសវៀតណាមចំនួន ២១០តោន ប្រទេសណេដឺឡែនចំនួន ១៥២តោន ប្រទេសកាណាដាចំនួន ១០២តោន ប្រទេសថៃចំនួន ៩៨,៦០តោន ប្រទេសម៉ាឡេស៊ីចំនួន ៣៨,៤០តោន ប្រទេសសិង្ហបុរីចំនួន ១៩តោន និងប្រទេសឥណ្ឌាចំនួន ១៧តោន
- កាកសំណល់ដំឡូងមីមានចំនួន ៧ ៩៣៥,៣៩តោន (កើនឡើងចំនួន ៣១,១៣%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៧ ៤៣៥,៣៩តោន និងប្រទេសវៀតណាមចំនួន ៥០០តោន
- គ្រាប់ស្វាយចន្ទីឆៅមានចំនួន ៤៦៨ ០១៥,១៥តោន (ថយចុះចំនួន -៤៧,៤៨%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៤៦៥ ៨០១,២២តោន ប្រទេសថៃចំនួន ២ ០៥០តោន ប្រទេសឥណ្ឌាចំនួន ១៥០,១៦តោន ប្រទេសចិនចំនួន ១៣,៥៨តោន ប្រទេសជប៉ុនចំនួន ០,១៤តោន និងប្រទេសហ្វីលីពីនចំនួន ០,០៥តោន
- គ្រាប់ស្វាយចន្ទីកែច្នៃមានចំនួន ៥៥៨,៧២តោន (ថយចុះចំនួន -៦១,៧៥%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ២៥៦,៤៤តោន ប្រទេសចិនចំនួន ២២៩,៨៤តោន ប្រទេសជប៉ុនចំនួន ៤៣,០៧តោន កោះតៃវ៉ាន់ចំនួន ២៤តោន ប្រទេសកូរ៉េចំនួន ៥,២៥តោន និងប្រទេសស្វីសចំនួន ០,១២តោន
- គ្រាប់ពោតមានចំនួន ១៤៨ ៣២៣,៩២តោន (ថយចុះចំនួន -៣,៩៧%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៩៩ ៤៤០តោន ប្រទេសថៃចំនួន ៤៨ ០០០តោន កោះតៃវ៉ាន់ចំនួន ៨៧១,៦២តោន និងប្រទេសកូរ៉េចំនួន ១២,៣០តោន

- គ្រាប់សណ្តែកបាយមានចំនួន ៣៥ ០២៥,០១តោន (កើនឡើងចំនួន ៣៨,២៧%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៣៥ ០២៥តោន និងប្រទេសជប៉ុនចំនួន ០,០១តោន

- គ្រាប់សណ្តែកសៀងមានចំនួន ៨៨ ០៨៥តោន (កើនឡើងចំនួន ២១៥,០៤%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៨១ ៦៣៥តោន និងប្រទេសថៃចំនួន ៦ ៤៥០តោន

- ផ្លែចេកស្រស់មានចំនួន ៣០៦ ២៥៥,១០តោន (ថយចុះចំនួន -១០,៩២%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ២៧៥ ៥០៣,៨៤តោន ប្រទេសវៀតណាមចំនួន ៣០ ៧៥១,២១តោន និងប្រទេសជប៉ុនចំនួន ០,០៥តោន

- ផ្លែស្វាយស្រស់មានចំនួន ១២៧ ២៣១,៥៥តោន (ថយចុះចំនួន -២៦,៣៩%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៦៧ ៩២០,២៣តោន ប្រទេសថៃចំនួន ៣១ ៦៨១,១២តោន ប្រទេសចិនចំនួន ២៧ ៤៦៧,៨៨តោន ប្រទេសកូរ៉េចំនួន ១៦០,០៨តោន និងទីក្រុងហុងកុងចំនួន ២,២៤តោន

- ដំណាប់ស្វាយមានចំនួន ១៥ ០៣៨,៣៦តោន (កើនឡើងចំនួន ៣,៩៩%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ១៣ ២០០,៩៥តោន ប្រទេសថៃចំនួន ៩១៨,៥៤តោន ប្រទេសហ្វីលីពីនចំនួន ៤៩៩,៩៦តោន ប្រទេសវៀតណាមចំនួន ២០០តោន ប្រទេសជប៉ុនចំនួន ១១១,៥៤តោន ប្រទេសរុស្ស៊ីចំនួន ៧១,០៥តោន ប្រទេសអ៊ីតាលីចំនួន ២១,៤២តោន ចក្រភពអង់គ្លេសចំនួន ៩,៧៨តោន ប្រទេសកូរ៉េចំនួន ៥,០៨តោន សហរដ្ឋអាមេរិកចំនួន ០,០៣តោន និងប្រទេសអូស្ត្រាលីចំនួន ០,០១តោន

- ដូងប្រេងមានចំនួន ៤៥ ៦១៨,៧០តោន (ថយចុះចំនួន -០,៣៩%) ក្នុងនោះនាំចេញទៅប្រទេសឥណ្ឌាចំនួន ៣៦ ៦៤៦,៧០តោន ប្រទេសម៉ាឡេស៊ីចំនួន ៧ ៩៨០តោន ប្រទេសវៀតណាមចំនួន ៨០០តោន និងប្រទេសថៃចំនួន ១៩២តោន

- ម្រេចមានចំនួន ៧ ៥៦៩,៧០តោន (ថយចុះចំនួន -៧២,២៩%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៦ ៥៩៨,៣៩តោន ប្រទេសអាល្លឺម៉ង់ចំនួន ៨៧៨,២០តោន កោះតៃវ៉ាន់ចំនួន ២១តោន ប្រទេសបារាំងចំនួន ១៨,៩១តោន ប្រទេសម៉ាឡេស៊ីចំនួន ១៣,៦៤តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ១៣,២៤តោន សាធារណរដ្ឋឆែកចំនួន ៩,៤៤តោន ប្រទេសកូរ៉េចំនួន ៤,៣៧តោន ប្រទេសជប៉ុនចំនួន ៣,០៣តោន ប្រទេសស៊ុយអ៊ែតចំនួន ២,៧៨តោន ប្រទេសស្វីសចំនួន ១,៦២តោន ប្រទេសកាណាដាចំនួន ១,២៨តោន សហរដ្ឋអាមេរិកចំនួន ១,១០តោន ប្រទេសឥណ្ឌាចំនួន ០,៩២តោន ចក្រភពអង់គ្លេសចំនួន ០,៩០តោន ប្រទេសលីទុយអានីចំនួន ០,៤៥តោន ប្រទេសកាហ្សាក់ស្ថានចំនួន ០,២៩តោន ប្រទេសអូស្ត្រាលីចំនួន ០,១០តោន ប្រទេសរុស្ស៊ីចំនួន ០,០៣តោន និងប្រទេសណេដឺឡែនចំនួន ០,០១តោន

- ថ្នាំជក់មានចំនួន ៥ ៤៨៧,២៥៤តោន (កើនឡើងចំនួន ១១៨,២៦%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៥ ៣៨៤,៧០តោន កោះតៃវ៉ាន់ចំនួន ៤៧,២៥តោន ប្រទេសហុងគ្រីចំនួន ៣៩,៦០តោន ប្រទេសហ្វីលីពីនចំនួន ១៥,១១តោន ប្រទេសអេស្ប៉ាញចំនួន ០,៥៧តោន ប្រទេសអាហ្វ្រិកខាងត្បូងចំនួន ០,០២តោន និងប្រទេសប៊ុលហ្គារីចំនួន ០,០០៤តោន

- បន្លែចម្រុះមានចំនួន ៧១,៩៥តោន (ថយចុះចំនួន -៧,១៦%) ក្នុងនោះនាំចេញទៅប្រទេសបារាំងចំនួន ៧១,៩១តោន និងប្រទេសនូវែលសេឡង់ចំនួន ០,០៤តោន

- ផលិតផលចំនួន ៩៣មុខ ផ្សេងទៀតមានចំនួន ៤២៨ ០៤៧,០៦តោន។

**១.៤.៤ ការប៉ាន់ស្មានតម្លៃនៃការនាំចេញកសិផល**

ការប៉ាន់ស្មានតម្លៃគិតជាទឹកប្រាក់រយៈពេល៩ខែឆ្នាំ២០២២ ដែលទទួលបានពីការនាំចេញកសិផល (ឯកតាតម្លៃផ្អែកតាមវិក្កយបត្ររបស់អ្នកនាំចេញ) មានចំនួន ២ ៩០២ ៤៣៨ ២៨៥,៥៧ដុល្លារអាមេរិក ដែលក្នុងនោះ៖

- ការនាំចេញអង្ករមានចំនួន ៣៨៤ ២០៣ ៦៥៥ដុល្លារអាមេរិក
- ការនាំចេញស្រូវមានចំនួន ៤៧៦ ២៤៩ ៥៤២ដុល្លារអាមេរិក
- ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករមានចំនួន ២ ០៤១ ៩៨៥ ០៨៨,៥៧ដុល្លារអាមេរិក។

## ២- ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ០៤៤ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មចំនួន ៤៧ ៩៤៤ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩២ ៤០២ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦៣ ៦៩៨ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ៣១០ ១៩៣ហ.ត ស្មើនឹង៧៧% និងផ្ទៃដីថែទាំចំនួន ៩៣ ៨៥១ហ.ត ស្មើនឹង២៣%។

២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូរយៈពេល៨ខែសម្រេចបានចំនួន ១៩៩ ៩២៩តោន បានថយចុះចំនួន ៥៣៧តោន ស្មើនឹង០,៣% ធៀបរយៈពេល៨ខែ ឆ្នាំ២០២១

- ផលិតផលឈើកៅស៊ូរយៈពេល៨ខែសម្រេចបានចំនួន ២២ ៣៧៦ម៣។

២.៣ ការនាំចេញកៅស៊ូ

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូរយៈពេល៨ខែសម្រេចបានចំនួន ១៩៩ ០១៤តោន កើនឡើងចំនួន ១ ៩៥៣តោន ស្មើនឹង១% ធៀបរយៈពេល៨ខែ ឆ្នាំ២០២១

- បរិមាណបញ្ចេញលក់ឈើកៅស៊ូរយៈពេល៨ខែសម្រេចបានចំនួន ២០ ៦២៩ម៣។

២.៤ តម្លៃកៅស៊ូ

- តម្លៃលក់ជ័រកៅស៊ូគិតជាមធ្យមរយៈពេល៨ខែគឺ១ ៥៥៣ដុល្លារ/តោន ថយចុះចំនួន ១១៩ដុល្លារ/តោន ស្មើនឹង៧% ធៀបរយៈពេល៨ខែ ឆ្នាំ២០២១

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារខែកក្កដា គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៥ ៤០០៛/គ.ក្រ ដល់ ៥ ៧០០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ៤២៥៛/គ.ក្រ ដល់ ៣ ២០០៛/គ.ក្រ។

## ៣- ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- ទាញយករូបភាពផ្កាយរណប (SENTINEL_2) ឆ្នាំ២០២២ ចំនួន ៥៤ផ្ទាំង និងបានចាត់បឋមសម្រាប់ចុះពិនិត្យជាក់ស្តែងនៅទីវាល

- ចុះធ្វើការប្រមូលព័ត៌មាននៅទីវាលជាក់ស្តែងតាមចំណុចនិយាមកាមួយចំនួនដែលបានធ្វើការចាត់ថ្នាក់បឋមតាមរូបភាពផ្កាយរណប SENTINEL-2 ក្នុងកម្មវិធី eCognition ហើយមានភាពមិនច្បាស់លាស់ ដើម្បីធ្វើការផ្ទៀងផ្ទាត់ និងវាយតម្លៃកម្រិតជឿជាក់ចំនួន ២ ១៥១ចំណុច

- ចេញសេចក្តីប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ឃុំស្រករថ្លុកឬស្សីពីរ មានផ្ទៃដីទំហំ ២៣២,១៥ហ.ត ស្ថិតនៅខេត្តកំពង់ធំ

- ចុះកំណត់តំបន់សក្តានុពលព្រៃសហគមន៍ចំនួន ៣កន្លែង នៅក្នុងខេត្តចំនួន ២ដែលមានផ្ទៃដីទំហំ ៦១១,៦៧ហ.ត (ព្រៃសហគមន៍ត្រពាំងប្រីយ៍ពីរមានផ្ទៃដីទំហំ ១៨៥,៩១ហ.ត ព្រៃសហគមន៍ព្រៃប៉ុស្តិ៍ពីរមានផ្ទៃដីទំហំ ១២២,៩១ហ.ត ស្ថិតនៅខេត្តកំពង់ធំ និងព្រៃសហគមន៍សាមគ្គីពីរមានផ្ទៃដីទំហំ ៣០២,៨៥ហ.ត ស្ថិតនៅខេត្តឧត្តរមានជ័យ)។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- ចុះសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ និងដំឡើងម៉ាស៊ីនថតរូបស្វ័យប្រវត្តិចំនួន ១៤គ្រឿង ដើម្បីចាប់យករូបភាពសត្វព្រៃគ្រប់ប្រភេទ កត្តាគំរាមកំហែង ព្រមទាំងបានចុះពិនិត្យសាកសពសត្វដំរី ១ក្បាល ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃកែវសីមា

- ចុះប្រមូលសំណាកសត្វថៃគីកកៃ និងថៃចេញពីសត្វស្រុក និងសត្វព្រៃនៅខេត្តកោះកុងចំនួន ១០០ក្បាល និងសំណាកសត្វប្រចៀវ ជ្រឹង ចំនួន ២លើក នៅខេត្តស្ទឹងត្រែង និងខេត្តកំពត ដោយប្រមូលសំណាក (ឈាម ទឹកមាត់ លាមក ទឹកនោម និងចោះស្បែក) សត្វប្រចៀវចំនួន ៤៦៥សំណាក

- ចុះពង្រឹងការថែរក្សាសត្វព្រៃចំនួន ២លើក គឺនៅខេត្តកំពង់ស្ពឺចំនួន ១លើក និងខេត្តក្រចេះចំនួន ១លើក ដោយដោះអន្ទាក់ចំនួន ៧៧ខ្សែ ចេញពីផ្លូវសត្វព្រៃឆ្លងកាត់ និងចុះសិក្សាកំណត់តំបន់សក្តានុពលទេសចរណ៍ធម្មជាតិចំនួន ២លើកនៅខេត្តមណ្ឌលគិរី

- ចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ៧២ច្បាប់ (លិខិត៥៤ច្បាប់សម្រាប់ថែរក្សាសត្វក្រចៀកកាំ និង១៨ច្បាប់សម្រាប់ការថែរក្សាសត្វព្រៃប្រភេទផ្សេង) ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ កំពង់ធំ សៀមរាប បន្ទាយមានជ័យ ក្រចេះ កំពង់ចំ ពោធិ៍សាត់ កណ្តាល កំពត និងខេត្តបាត់ដំបង

- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃជូនក្រុមហ៊ុនចំនួន ៥២ច្បាប់ មានស្វាក្តាមចំនួន ២៤ ៨៦៨ក្បាល សម្រាប់ដឹកជញ្ជូនទៅកាន់មាត់ច្រកអន្តរជាតិនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញចំនួន ២០ ០០១ក្បាល និងដឹកជញ្ជូនក្នុងស្រុកចំនួន ៤ ៨៦៧ក្បាល។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៧ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៨ទីតាំង ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមាន ស្វាក្តាមសរុបចំនួន ១៣៧ ៣៥៩ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៧៣ ០១៦ក្បាល

- កំពុងថែរក្សាសត្វព្រៃសរុបចំនួន ១ ៨២៧ក្បាល សង្គ្រោះសត្វថ្មីចំនួន ៤២៧ក្បាល ព្យាបាលសត្វព្រៃ ចំនួន ២១៦ក្បាល (បក្សី៥៩ប្រភេទ ថនិកសត្វ៤៤ប្រភេទ និងល្មូន១៦ប្រភេទ) និងបានស្តារលទ្ធភាពជីវសាស្ត្រ សត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញចំនួន ៧៧ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI ក្រុមល្បាតចំនួន ២៦នាក់ ចុះល្បាតនៅ តំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៥គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់) រកឃើញលាមកក្រពើចំនួន ៦៦ដុំ ឃើញក្រពើផ្ទាល់ចំនួន ២ក្បាល និងស្លាកស្នាម ជានជើងចំនួន ៤កន្លែង និងប្រលែងក្រពើភ្នំពូជសុទ្ធចំនួន ២៥ក្បាលទៅក្នុងស្ទឹងធម្មជាតិក្នុងភូមិពោធិ៍បឹង ឃុំជងពែង ស្រុកស្រែអំបិល ខេត្តកោះកុង

- សិក្សាស្រាវជ្រាវវត្តមានក្រពើភ្នំនៅតំបន់ឆាយរាប ដោយរកឃើញសំបុកពងក្រពើចំនួន ១មានពងចំនួន ២២គ្រាប់

- ជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង ១៦ ២៣៨ម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃទំហំ ៤,៥ហ.ត។

### ៣.៤ ការងារដាំដើមឈើ

- សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពត និងមន្ទីរជំនាញពាក់ព័ន្ធចុះបញ្ជីដី ទំហំ៤៧ហ.ត៦៧៧៥ ដើម្បីបង្កើតសួនភូតគាមស្ថិតក្នុងឃុំស្តេចគង់ខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត។ ស្នើសុំ ការពិនិត្យសម្រេចសេចក្តីព្រាងប្រកាសស្តីពីការបង្កើតស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើចំនួន ៣ទីតាំងមាន ផ្ទៃដីទំហំ២២ ៥៦៦ហ.ត៣០៤៧ ស្ថិតនៅខេត្តពោធិ៍សាត់ និងខេត្តក្រចេះ

- ចុះធ្វើសារពើភ័ណ្ឌក្នុងចម្ការឈើដាំទំហំ២០០ហ.ត ក្នុងនោះនៅស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើខ្នាររង្គាស់ ខេត្តសៀមរាប បានដាំនៅក្នុងឆ្នាំ២០១៤ និង២០១៥ លើផ្ទៃដីទំហំ១០០ហ.ត និងចម្ការឈើដាំនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ បានដាំនៅក្នុងឆ្នាំ២០១៥ លើផ្ទៃដីទំហំ១០០ហ.ត

- ដាំឈើជាចម្ការថ្មីទំហំ១១០ហ.ត ក្នុងនោះនៅខេត្តកំពង់ធំទំហំ៧៥ហ.ត និងខេត្តកំពង់ឆ្នាំងទំហំ៣៥ហ.ត

- បាននិងកំពុងថែទាំចម្ការឈើទំហំ៧៤៧ហ.ត ក្នុងនោះមានចម្ការពូជឈើទំហំ៩៤ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្មទំហំ៣៩ហ.ត ចម្ការឈើដាំទំហំ៥៨៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដា សរុបទំហំ៣០ហ.ត ស្ថិតក្នុងខេត្តកំពត កណ្តាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- ដាំកូនឈើសរុបចំនួន ១៣ ៩៤០ដើម ក្នុងនោះមានធ្នង់៤ ៦៨៩ដើម ច្រេស១ ៥០០ដើម គីនីន២ ០០០ដើម គ្រញូង៣ ២០០ដើម ឈើទាល១៤០ដើម ម៉ៃសាក់៦០០ដើម និងប្រេងខ្យល់១៨១១ដើម។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុម អន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន ៦ ៣១១ករណី ក្នុងនោះសំណុំរឿងបទល្មើស ព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន ១៩០ករណី និងសំណុំរឿងបទល្មើសព្រៃឈើត្រូវបញ្ជូនទៅតុលាការចំនួន ៤៤១ករណី

- វត្ថុតាងនៃបទល្មើសព្រៃឈើបានចាប់ឃាត់ និងដកហូត រួមមាន ឈើអារចំនួន ៨៦៤ម៣ ឈើមូល-ជ្រុង ចំនួន ១២៥ម៣ ផ្ទៃដីព្រៃឈើបានកាប់រានទំហំ ៤ ៤៦២ហ.ត វត្ថុតាងសត្វព្រៃបានចាប់ឃាត់ចំនួន ៣ ៨១៧ក្បាល និង៦០២គ.ក្រអនុផលព្រៃឈើ ឧបករណ៍ និងសម្ភារមួយចំនួនទៀត

- វត្ថុតាងសត្វព្រៃ និងសំណាកសត្វព្រៃដែលពុំមានចងក្រងសំណុំរឿង រួមមាន បានប្រគល់-ទទួលចំនួន ៣០៣ករណី ធ្វើកិច្ចសន្យាចំនួន ៨៥ករណី ធ្វើការដកហូតសរុបចំនួន ៧៦ករណី

- ធ្វើបច្ចុប្បន្នភាពសំណុំរឿងបទល្មើសព្រៃឈើ និងសត្វព្រៃតាមរយៈការបង់ប្រាក់ពិន័យដោយតុលាការ ចំនួន ២២ករណី។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ចុះពិនិត្យសំណើសុំបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ប្រកចេញចូល តែមួយ) ចំនួន ២កន្លែងស្ថិតនៅខេត្តកំពត និងខេត្តតាកែវ និងពន្យារសុពលភាពចំនួន ១២កន្លែងស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តកណ្តាល ស្វាយរៀង បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ ព្រៃវែង កំពង់ធំ សៀមរាប និងខេត្តកំពង់ចាម

- ពិនិត្យសំណើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ៣កន្លែងស្ថិតនៅខេត្តស្ទឹងត្រែង និងខេត្តព្រះសីហនុ និងពន្យារសុពលភាពចំនួន ៩កន្លែងស្ថិតនៅរាជធានីភ្នំពេញ ខេត្តត្បូងឃ្មុំ កំពង់ធំ សៀមរាប ព្រះសីហនុ ព្រះវិហារ ក្រចេះ និងខេត្តមណ្ឌលគិរី

- ក្រុមហ៊ុនចំនួន៩នាំចេញផលិតផលរានទេវតា និងឈើអារកែច្នៃទៅក្រៅប្រទេសចំនួន ១ ១៤០ម៣ ជ័រទឹកចំនួន ១១៤តោន ធ្យូងអាកាស្យាចំនួន ៨១តោន និងចំណាំងកម្ទេចឈើចំនួន ៩ ០០០តោន និងក្រុមហ៊ុន ចំនួន៣បាននាំចូលឈើកែច្នៃចំនួន ១ ៤៦៤ម៣

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន១០មានឈើកែច្នៃចំនួន ១២៧១ម៣ ចំណាំងកម្ទេចឈើចំនួន ៩០០០តោន គ្រឿងសង្ហារឹមឫស្សីកែច្នៃចំនួន ៦១តោន ជ័រទឹកចំនួន ១៦១តោន និងធ្យូងអាកាស្យាចំនួន ៨៨តោន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន៣មានឈើកែច្នៃចំនួន ១ ៩៩៦ម៣ បានពន្យារទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន១មានឈើកែច្នៃចំនួន ២៨ម៣

- ពន្យារទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន១មានឈើកែច្នៃចំនួន ១៥២ម៣។

### ៣.៧ ការងារចំណូលព្រៃឈើ

- ចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួនសរុប ៣ ៣៥០ ៩៤១ ៨៨៩រៀល និង៨៣០ ៧២០,០៩ដុល្លារ។

## ៤- ផ្នែកសុខភាពសត្វ និងផលិតកម្មសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

**៤.២.១ លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** ចុះត្រួតពិនិត្យទប់ស្កាត់ និងបង្ក្រាបបទល្មើសចលនាសត្វ និងផលិតផលសត្វសរុបបានចំនួន ១៣៤ករណី ក្នុងនោះ ត្រួតពិនិត្យមានលិខិតអនុញ្ញាតត្រឹមត្រូវ១០១ករណី និងមិនមានលិខិតអនុញ្ញាតត្រឹមត្រូវ៣៣ករណី។ រាជធានី-ខេត្តចំនួន ២៥ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១៧៦ ៤២៧លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។

**៤.២.២ ការងារផ្សព្វផ្សាយបច្ចេកទេស**

- ចុះប្រជុំផ្សព្វផ្សាយស្តីពីបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន៤

- ចុះឃោសនាផ្សព្វផ្សាយស្តីពីជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន៨ និងចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន៤។

**៤.២.៣ ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេសនិងនីតិកម្មលើសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ

- ចុះពិនិត្យ និងតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅតាមបណ្តាខេត្តចំនួន១១។

**៤.៣ ការងារស្រាវជ្រាវ**

៤.៣.១ ការងារស្រាវជ្រាវផលិតកម្ម៖ បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១២០ក្បាល។

៤.៣.២ ការងារស្រាវជ្រាវសុខភាពសត្វ៖ ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបបានចំនួន ១៩ ៨៣៧វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) និងជំងឺដុំពកស្បែកគោ ក្របី (LSD)។ វត្ថុវិភាគចំនួន ២១ដែលមានប្រភពមកពីភូមិលេខ៦ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ភូមិទ័ពស្តេច ឃុំជាយ ស្រុកបាភ្នំ ខេត្តព្រៃវែង និងបឹងស្នេហ៍ខេត្តព្រៃវែង វិជ្ជមាន H5N1 ។ វត្ថុវិភាគចំនួន ៤ដែលមានប្រភពមកពីភូមិត្រពាំងរុន ឃុំឬស្សីលក ស្រុកជីក្រែង ខេត្តសៀមរាប វិជ្ជមាន H9N2 វត្ថុវិភាគចំនួន ១៧ដែលមានប្រភពមកពីសង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ភូមិក្រជាស ឃុំតាំងក្រសាំង ស្រុកបាធាយ ខេត្តកំពង់ចាម ភូមិត្រែង ឃុំអំពិល ស្រុករមាសហែក ខេត្តស្វាយរៀង ភូមិក្រពើគម ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម ខេត្តតាកែវ សៀមរាប កំពង់ចាម និងខេត្តត្បូងឃ្មុំ វិជ្ជមានជំងឺដុំពកស្បែកគោក្របី (LSD) ។ វត្ថុវិភាគចំនួន ១៦ដែលមានប្រភពមកពីប្រទេសវៀតណាមតាមរយៈការនាំចូលជ្រូករស់ខុសច្បាប់មានវត្តមានមេរោគជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។

## ៥- វិស័យជលផល

**៥.១ អាជីវកម្មនេសាទ**

៥.១.១ នេសាទទឹកសាប

- ដាយត្រីសម្រេចបានចំនួន ៦៥០តោន ស្មើនឹង៦,៥០% នៃផែនការចំនួន ១០ ០០០តោន ប្រៀបធៀបនឹងឆ្នាំមាស ឆ្នាំ២០២១ ថយចុះចំនួន ៦៦០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ១៤៧ ៦០០តោន ស្មើនឹង៤៩,២០% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបនឹងឆ្នាំមាស ឆ្នាំ២០២១ ថយចុះចំនួន ៣៧ ៤០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៤៣ ៨០០តោន ស្មើនឹង៣១,២៩% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបនឹងឆ្នាំមាស ឆ្នាំ២០២១ កើនឡើងចំនួន ៧ ៨០០តោន។

៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៨៩ ៤០០តោន ស្មើនឹង៦៨,៧៧% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបនឹងឆ្នាំមាស ឆ្នាំ២០២១ កើនឡើងចំនួន ១ ៦០០តោន។

**៥.២ វារីវប្បកម្ម**

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ២៤៦ ០០០តោន ស្មើនឹង៦៨,៣៣% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបនឹងឆ្នាំមាស ឆ្នាំ២០២១ កើនឡើងចំនួន ៩១ ៣០០តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ១០៨ ០០០ក្បាល ស្មើនឹង៣៦% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបនឹងឆ្នាំមាស ឆ្នាំ២០២១ ថយចុះចំនួន ១៣៩ ៨០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ១៥៨ ៥០០ ០០០កូន ស្មើនឹង៥២,៨៣% នៃផែនការចំនួន ៣០០ ០០០ ០០០កូន ប្រៀបធៀបនឹងឆ្នាំមាសឆ្នាំ២០២១ ថយចុះចំនួនប្រមាណ ១១៥ ០២៩ ៩៣៨កូន។

**៥.៣ ការកែច្នៃផលនេសាទ**

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៣៦ ៥០០តោន ស្មើនឹង៤៥,៦៣% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបនឹងឆ្នាំមាស ឆ្នាំ២០២១ ថយចុះចំនួន ៣ ៥៥០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ៨ ៥៦០តោន ស្មើនឹង៧១,៣៣% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបនឹងឆ្នាំមាស ឆ្នាំ២០២១ កើនឡើងចំនួន ៦០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៤០ ៧៥០ ០០០លីត្រ ស្មើនឹង៨១,៥០% នៃផែនការចំនួន ៥០ ០០០ ០០០លីត្រ ប្រៀបធៀបនឹងឆ្នាំមាស ឆ្នាំ២០២១ ថយចុះចំនួន ២៧២ ០០០លីត្រ។

**៥.៤ ការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសជលផល**

- សំណុំរឿងបទល្មើសជលផលមានចំនួន ១ ៧១៦ករណី ប្រៀបធៀបនឹងឆ្នាំមាស ឆ្នាំ២០២១ ថយចុះចំនួន ៣៤៨ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១ ៥៩៧ករណី និងសមុទ្រចំនួន ១១៩ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ២ ២៤២តោន ស្មើនឹង២៨,០៣% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២១ ថយចុះចំនួន ៤៣៥តោន

- ផលនេសាទកែច្នៃនាំចេញចំនួន ៤១តោន ស្មើនឹង២,០៥% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២១ ថយចុះចំនួន ១០៩តោន។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលបានចំនួន ៤៧៩ ០០៧ ៧៨៣រៀល ស្មើនឹង១៣៣,៣៥% នៃផែនការចំនួន ៣៥៩ ២០០ ០០០រៀល ប្រៀបធៀបនឹងឆមាស ឆ្នាំ២០២១ កើនឡើងចំនួន ១២ ៩១៥ ៣៥៩រៀល។

## ៦- ផ្នែកអធិការដ្ឋាន

- ចុះពិនិត្យ និងវាយតម្លៃលើការងារបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងជលផលនៅខេត្តកែប និងខេត្តកំពត

- ចុះពិនិត្យតាមដាន និងវាយតម្លៃលើការងារបង្ក្រាបបទល្មើសជលផលនៅខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ធំ កំពង់ឆ្នាំង និងខេត្តពោធិ៍សាត់

- ចុះធ្វើអធិការកិច្ចលើការអនុវត្តតួនាទី ភារកិច្ច ការផ្តល់សេវាសាធារណៈ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈនៅខេត្តកំពង់ចាម

- ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផល ផលិតផលជលផលនាំចូល នាំចេញ និងឆ្លងកាត់គ្មានការអនុញ្ញាតនៅខេត្តព្រៃវែង និងខេត្តកណ្តាល

- ទទួលពាក្យបណ្តឹងចំនួន ៣ករណី

- ស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៧៩៤ករណី លើវិស័យព្រៃឈើ ២២០ករណី ជលផល២៦៤ករណី សុខភាពសត្វនិងផលិតកម្មសត្វ៧៥ករណី កៅស៊ូ៨ករណី អគ្គនាយកដ្ឋានកសិកម្ម ៤ករណី ក្សេត្រសាស្ត្រ៦ករណី នីតិកម្ម៥ករណី និងវិស័យផ្សេងៗ២១២ករណី។

## ៧- ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៦ ២៥២ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ២ ៤៤៣ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ២ ៧៨៧ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១ ០២២ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៩ ៤០៣ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៤៤៧ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ២១០ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំឆមាស

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំ ដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- រៀបចំកិច្ចប្រជុំផ្ទៃក្នុង (អន្តរនាយកដ្ឋាន) ចំនួន ៧៨លើក មានសមាជិកចូលរួមចំនួន ២ ៨៧៦នាក់ និងកិច្ចប្រជុំអន្តរក្រសួងចំនួន ១២លើក មានសមាជិកចូលរួមចំនួន ១៨៣នាក់

- ទទួលភ្ញៀវអន្តរជាតិចំនួន ២២លើក មានសមាជិកចូលរួមចំនួន ១០៥នាក់

- សិក្ខាសាលាចំនួន ៩លើក មានសមាជិកចូលរួមចំនួន ១ ១១៤នាក់

- ពិធីចុះហត្ថលេខាចំនួន ៣លើក មានសមាជិកចូលរួមចំនួន ២៩៥នាក់

- សរុបការរៀបចំកិច្ចប្រជុំ ការទទួលភ្ញៀវ ពិធីចុះហត្ថលេខា និងសិក្ខាសាលាមានចំនួន ១១២លើក មានសមាជិកចូលរួមចំនួន ៣ ២៧៨នាក់

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញ ផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារ កសិកម្ម)។

## ៨- ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៩៣១នាក់ (ស្រី១ ៤៧៧នាក់ ស្មើនឹង២៤,៩០%) រួមមាន៖
  - + អង្គភាពថ្នាក់កណ្តាលចំនួន ៣ ០០៧នាក់ (ស្រី៨៧២នាក់ ស្មើនឹង២៨,៩៩%)
  - + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩២៤នាក់ (ស្រី៦០៥នាក់ ស្មើនឹង២០,៦៩%)
- តែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ១៣៩នាក់ (ស្រី២៩នាក់)
- ផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការ និងលុបឈ្មោះចេញពីក្របខ័ណ្ឌសរុបចំនួន ៩៨នាក់ (ស្រី១៩នាក់)
- ចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកជូនមន្ត្រីរាជការសរុបចំនួន ៧៧នាក់ (ស្រី៤០នាក់)
- រៀបចំប្រកាសស្តីពីការដាក់មន្ត្រីរាជការចូលនិវត្តន៍តាមកាលកំណត់ចំនួន ១០នាក់
- រៀបចំលិខិតស្នើសុំដំឡើងឋានន្តរសក្តិ និងថ្នាក់តាមសញ្ញាបត្រសម្រាប់ឆ្នាំ២០២២ ចំនួន ៧៧៩នាក់
- រៀបចំប្រកាសស្តីពីការដាក់មន្ត្រីរាជការស្ថិតនៅភាពទំនេរគ្មានបៀវត្សចំនួន ៣៤នាក់
- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ២ ១៩៤នាក់ (ស្រី៦១៤នាក់) ក្នុងនោះ៖
  - + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ២ ០៦៣នាក់ (ស្រី៥៩១នាក់)
  - + ការបណ្តុះបណ្តាលក្រៅប្រទេសចំនួន ១៣១នាក់(ស្រី២៣នាក់) ។

## ៩- ផ្នែកផែនការ និងស្ថិតិ

- ចូលរួមកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ឆ្នាំ២០១៩-២០២៣
- រៀបចំសំណើសុំរបាយការណ៍សង្ខេបស្តីពីសកម្មភាពការងារដែលជាសមិទ្ធផលសំខាន់ៗសម្រេចបានរយៈពេល ៥ឆ្នាំ (២០១៧-២០២១) របស់ក្រសួង ស្ថាប័ន អាជ្ញាធរ និងរដ្ឋបាលរាជធានី-ខេត្ត
- រៀបចំសំណើសុំផ្តល់យោបល់លើសេចក្តីព្រាងគោលនយោបាយជាតិស្តីពីស្វាយចន្ទីឆ្នាំ២០២២-២០២៧
- រៀបចំសេចក្តីព្រាងគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២២-២០៣០
- រៀបចំលិខិតផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ ទៅអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត
- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងសប្តាហ៍រៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តទាំង២៥
- ចុះពិនិត្យ និងតាមដានការស្រង់ព័ត៌មានតម្លៃទីផ្សារកសិកម្មនៅខេត្តបាត់ដំបង ព្រះវិហារ ឧត្តរមានជ័យ និងខេត្តប៉ៃលិន
- ចុះសិក្សាស្ថានភាពផលិតផល និងទីផ្សារកសិកម្មនៅខេត្តព្រះវិហារ មណ្ឌលគិរី ឧត្តរមានជ័យ និងខេត្តរតនគិរី
- ចុះតាមដាន និងវាយតម្លៃការអនុវត្តសកម្មភាពថវិកាកម្មវិធីចំនួន៨ខេត្ត រួមមាន ខេត្តកំពង់ចាម ព្រះវិហារ រតនគិរី តាកែវ កែប ស្វាយរៀង កោះកុង និងខេត្តសៀមរាប
- ចុះត្រួតពិនិត្យ និងវាយតម្លៃផ្នែកបរិស្ថាន និងសង្គមគម្រោង CERC-MAFF និងប្រមូលព័ត៌មានរៀបចំក្រមប្រតិបត្តិបរិស្ថាន (ECOP) គម្រោង CERC ក្រមខ័ណ្ឌ MoWRAM នៅខេត្តកំពង់ឆ្នាំង បាត់ដំបង សៀមរាប និងខេត្តព្រះវិហារ។

## ១០- ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) សរុបទឹកប្រាក់ចំនួន ២៧ ៣៦៨លានរៀល ស្មើនឹង៧៣,៦% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២
- បញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបចំនួន ៨០ ៦៥៩លានរៀល ស្មើនឹង៥២,៥% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២២
- រៀបចំសំណើសុំថវិកាចំនួន ៤ ៣៦១ ៣០០ ០០០រៀល ដើម្បីទូទាត់ជូននាយកដ្ឋានវិស្វកម្មកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម សម្រាប់ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព (ស្ថានីយបូមទឹកបណ្តែត អាងស្តុក

ទឹកបឋម ជីកស្រះ បុកអណ្តូង ភ្ជាប់បណ្តាញទុយោទឹក និងភ្ជាប់បណ្តាញអគ្គិសនី) នៅតាមបណ្តាសហគមន៍កសិកម្ម ចំនួន៨នៅក្នុងខេត្តកំពង់ស្ពឺ កណ្តាល កំពង់ចាម ត្បូងឃ្មុំ និងខេត្តកំពង់ឆ្នាំង

- ទទួលបង្កាន់ដៃបង់ប្រាក់ថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ៨៥ក្រុមហ៊ុន
- ចុះពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីគណនេយ្យឆ្នាំ២០២១ របស់វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ ខេត្តស្វាយរៀង សៀមរាប ឧត្តរមានជ័យ កែប ត្បូងឃ្មុំ បន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ កំពង់ធំ កោះកុង ខេត្តកណ្តាល
- រៀបចំឯកសារសម្រាប់ដំណើរការដេញថ្លៃសរុបចំនួន ១៧គម្រោង
- ចូលរួមតាមដានការប្រើប្រាស់ ការកត់ត្រាទិន្នន័យ និងគ្រប់គ្រងការបញ្ចូលទិន្នន័យទ្រព្យសម្បត្តិរដ្ឋក្នុងប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (SARMIS) របស់អង្គភាពថ្នាក់កណ្តាល មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះសីហនុ និងខេត្តកំពង់ចាម
- ចុះពិនិត្យ និងផ្ទៀងផ្ទាត់តារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋសម្រាប់ឆ្នាំ២០២១ របស់អង្គភាពថ្នាក់កណ្តាល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ ខេត្តកំពង់ចាម កែប ព្រះសីហនុ ត្បូងឃ្មុំ បន្ទាយមានជ័យ ឧត្តរមានជ័យ បាត់ដំបង ស្វាយរៀង ប៉ៃលិន សៀមរាប ពោធិ៍សាត់ ព្រះវិហារ កំពត កំពង់ធំ កោះកុង កណ្តាល កំពង់ស្ពឺ តាកែវ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

## ១១- ផ្នែកសវនកម្មផ្ទៃក្នុង

- រៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះក្នុងឆ្នាំ២០២១ ធ្វើសំណើសុំជម្រះសម្ភារខូចខាតប្រើប្រាស់លែងកើត និងធ្វើការគ្រប់គ្រង បែងចែកសម្ភារការិយាល័យ សង្ហារិម សម្ភារបរិក្ខារបច្ចេកទេសថែទាំ និងជួសជុល
- រៀចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស
- ចុះធ្វើសវនកម្មចំនួន ២៦សវនដ្ឋាន ស្មើនឹង៦៦,៦៦% នៃផែនការ៣៩សវនដ្ឋាន ដោយរកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន៩២អនុសាសន៍ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៥៥,៨៥% នៃផែនការចំនួន៥៦%។

## ១២- ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- សម្របសម្រួលរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-នូវែលសេឡង់ ដើម្បីត្រៀមរៀបចំកិច្ចពិគ្រោះយោបល់ក្រសួងការបរទេសកម្ពុជា-នូវែលសេឡង់លើកទី២
- សម្របសម្រួលរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យ វាយតម្លៃហានិភ័យផ្លែមៀនកម្ពុជាសម្រាប់ការនាំចេញទៅកាន់ប្រទេសចិន
- សម្របសម្រួលដើម្បីបន្តសុពលភាពអនុស្សរណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម និងកសិ-ពាណិជ្ជកម្មរវាងក្រសួងកសិកម្មហ្វីលីពីន
- សម្របសម្រួលធ្វើលិខិតជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិសុំផ្តល់មតិយោបល់/ធាតុចូលលើសេចក្តីព្រាងឯកសារផែនការសកម្មភាព៥ឆ្នាំ នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងឆ្នាំ២០២៣-២០២៧
- សម្របសម្រួលលិខិតករណីសំណើផ្តល់ធាតុចូលលើវិស័យអាទិភាពដែលស្នើឡើងដោយកម្ពុជា សម្រាប់ផែនការការងារនៃកិច្ចសហប្រតិបត្តិការអាស៊ានបូកបីឆ្នាំ២០២៣-២០២៧
- សម្របសម្រួលការចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើដំណាំឧស្សាហកម្មចេករវាងកម្ពុជា-ចិន
- សម្របសម្រួលការចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការកម្មវិធីកសិករតាមរដូវកាលរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងខេត្ត Yanggu របស់ប្រទេសកូរ៉េ
- សម្របសម្រួលសុំគោលការណ៍អនុញ្ញាតចុះហត្ថលេខាអនុស្សរណៈនៃការយោគយល់គ្នារវាងវិទ្យាស្ថាននិងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ និងវិទ្យាស្ថានព្រៃឈើអាស៊ាននៃប្រទេសកូរ៉េ។

## ១៣- ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៤០ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២១៥ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចេញជីកសិកម្មចំនួន ១ក្រុមហ៊ុន

- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៦៧ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧៨ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ១៩ក្រុមហ៊ុន។

**១៣.២ ការងារមន្ទីរពិសោធន៍**

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៨៦ក្រុមហ៊ុន សរុបចំនួន ៧០៣សំណាក។

**១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត**

- សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈនៅខេត្តកំពង់ធំ ព្រះវិហារ កំពង់ចាម ត្បូងឃ្មុំ កណ្តាល សៀមរាប និងខេត្តកំពត។

**១៣.៤ ការងារអនុវត្តច្បាប់**

- ចុះត្រួតពិនិត្យក្រុមហ៊ុនប្រកាសប្រតិវេទន៍នាំចូលថ្នាំកសិកម្ម ជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយដល់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧២ក្រុមហ៊ុន។

## ១៤- ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- តាមដាន និងផ្សព្វផ្សាយលើគេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត លើគេហទំព័រសរុបចំនួនផុស ៤ ៣៤៦ព័ត៌មាន
- បន្តជំរុញការផ្សព្វផ្សាយឯកសារបច្ចេកទេសកសិកម្ម សេចក្តីជូនដំណឹង សារាចរណែនាំ សេចក្តីសម្រេច ប្រកាស និងលិខិតបទដ្ឋានគតិយុត្ត ឲ្យបានទូលំទូលាយលើបណ្តាញផ្សព្វផ្សាយសង្គម (ហ្វេសប៊ុក) និងគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសរុបចំនួន១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត
- ចុះតាមដាន និងពង្រឹងការប្រើប្រាស់គេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រមូលធាតុចូលសម្រាប់បង្កើតកម្មវិធីទូរស័ព្ទ នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន៨ រួមមាន ខេត្តកំពង់ស្ពឺ តាកែវ កោះកុង កែប កំពង់ចាម ស្វាយរៀង ព្រៃវែង និងខេត្តត្បូងឃ្មុំ
- តាមដាន និងថែទាំម៉ាស៊ីន Firewall ដើម្បីទប់ស្កាត់ការយាយីពីអ្នកខាងក្រៅ (Hacker)
- ទទួលសៀវភៅឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តីដែលទទួលបានពីរដ្ឋបាល និងផ្នែកផ្សេងៗសរុបចំនួន៤៣៩ក្បាល/ច្បាប់
- ការផ្សព្វផ្សាយអំពីបណ្ណាល័យកសិកម្មអេឡិចត្រូនិកមានអ្នកចូលអានចំនួន ៧២ ២៥២ដង/នាក់។

## ១៥- ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ចុះថត និងផលិត Video បទយកការណ៍ចំនួន ៨ប្រធានបទ
- ធ្វើការចាក់ផ្សាយឡើងវិញវេទិកាស្វែងយល់អំពីកសិកម្មចំនួន ៨ប្រធានបទ
- ធ្វើការចាក់ផ្សាយឡើងវិញនាទីចុះស្រែជាមួយកសិករចំនួន ៨ប្រធានបទ
- ធ្វើការចាក់ផ្សាយអត្ថបទបច្ចេកទេសកសិកម្មជាសំឡេងនៅស្ថានីយវិទ្យុជាតិ FM105.70.75MHZ ចំនួន ៥៤ប្រធានបទ
- គេហទំព័រ www.khmeragri.info/www.deaff.maff.gov.kh មានអ្នកទាញយកឯកសារផ្សេងៗចំនួន ២៥១ ២៨៤ដង អ្នកចូលមើលចំនួន ៧៩៣ ៥២៦នាក់ និងដាក់បញ្ចូលឯកសារសរុបចំនួន ៨១២ឯកសារ
- ជួយដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជនចំនួន ៥៩១សំណួរ-ចម្លើយលើប្រធានបទបច្ចេកទេសដំណាំកាហ្វេ ផ្សិតចំបើង ដំឡូងមី ដំឡូងជ្វា ពោត ម្ទេស ក្រូចឆ្មា ក្រូចថ្លុង សណ្តែក និងស្ពៃ ផ្តល់ព័ត៌មានជូនកសិករនូវសៀវភៅឯកសារចិញ្ចឹមត្រីប្រា ត្រីឆ្តោ កង្កែប កន្ធាយ ទា មាន់ និងជំងឺដុំពកលើសត្វគោ។

## ១៦- ផ្នែកកសិ-ឧស្សាហកម្ម

- អនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មចំនួន ២៦០កិច្ចសន្យា រួមមាន ខេត្តពោធិ៍សាត់៤២កិច្ចសន្យា ស្ទឹងត្រែង ៧កិច្ចសន្យា តាកែវ១៥កិច្ចសន្យា មណ្ឌលគិរី១កិច្ចសន្យា កំពង់ស្ពឺ៣៦កិច្ចសន្យា កែប៤កិច្ចសន្យា កណ្តាល១៥កិច្ចសន្យា ក្រចេះ១៤កិច្ចសន្យា ព្រះវិហារ៣៧កិច្ចសន្យា ត្បូងឃ្មុំ២០កិច្ចសន្យា សៀមរាប១១កិច្ចសន្យា កំពង់ចាម៤កិច្ចសន្យា

ស្វាយរៀង៣កិច្ចសន្យា បន្ទាយមានជ័យ១៥កិច្ចសន្យា កំពង់ធំ៨កិច្ចសន្យា កំពង់ឆ្នាំង១៦កិច្ចសន្យា និងខេត្តប៉ៃលិន ១២កិច្ចសន្យា

- ចុះសម្ភាសន៍ និងប្រមូលសំណាកត្រី ទឹក និងរកវត្តមានបាក់តេរី ក្នុងគម្រោង ARSF II, ACIAR/ Australia

- ចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីការភ្ជាប់ទំនាក់ទំនងកសិករខ្នាតតូចទៅនឹងទីផ្សារតាមរយៈផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តកំពង់ឆ្នាំង និងខេត្តបន្ទាយមានជ័យ

- ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តសៀមរាប និងខេត្តតាកែវ

- ចុះបណ្តុះបណ្តាលស្តីពីការលើកកម្ពស់ស្តង់ដារគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្មនៅខេត្តរតនគិរី និងខេត្តក្រចេះ

- បាននិងកំពុងសិក្សាស្រាវជ្រាវឯកសារបន្ថែមដែលពាក់ព័ន្ធនឹងនីតិវិធីនៃការអនុវត្តសេចក្តីព្រាងច្បាប់គុណភាព និងសុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារ

- ពិនិត្យឡើងវិញនូវរាល់ឈ្មោះសារធាតុគីមីដែលបានប្រើប្រាស់រួច និងរៀបចំផែនការស្នើសុំបញ្ជាទិញថ្មីសម្រាប់ឆ្នាំ២០២២

- បញ្ចូលទិន្នន័យ និងវាយតម្លៃលើផលិតផលចំនួន ៥០០ប្រភេទដែលទទួលបានពីការស្ទង់មតិពី៥រាជធានី-ខេត្ត រួមមាន ខេត្តសៀមរាប ព្រៃវែង កំពត ស្ទឹងត្រែង និងរាជធានីភ្នំពេញ

- បាននិងកំពុងពិភាក្សាពិគ្រោះយោបល់ និងរៀបចំពិធីការជាមួយអ្នកជំនាញការបច្ចេកទេស MRLs ដើម្បីអនុវត្តន៍ការសិក្សាស្រាវជ្រាវការកាត់បន្ថយកម្រិតកាកសំណល់ថ្នាំកសិកម្មក្នុងការដាំដុះប្រភេទជីនាងវងដោយប្រើប្រាស់ថ្នាំពុលកសិកម្ម ក្លរភីរីហ្វូស និងសាយភឺមេហ្រ៊ីន

- វិភាគរកសមាសធាតុគីមី លោហៈធ្ងន់ អាសេនិច(As) បារត(Hg) សំណរ(Pb) និងកាឌីដ្យូម(Cd) នៅក្នុងអង្ករចំនួន ២ប្រភេទ

- វិភាគរកសមាសធាតុកាកសសៃ សំណើម ផេះ ខ្លាញ់ អាស៊ូត កាបូនហ្ស៊ីត្រាដ ប្រូតេអ៊ីន និងសារធាតុរ៉ែផ្សេងៗទៀតដូចជា កាល់ស្យូម ដែក សូដ្យូម ប៉ូតាស្យូម ម៉ាញ៉េស្យូម ផូស្វ័រ និង Aflatoxin នៅក្នុងអង្ករចំនួន ២ប្រភេទ។

## ១៧- ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ប្រមូលប្រភេទពូជដំណាំថ្មីៗបន្ថែមទៀតបានចំនួន ៦ប្រភេទ សរុបមានចំនួន ៨៤សំណាក ឪឡឹក២សំណាក ម្ទេស១៥សំណាក ត្រឡាច១សំណាក ល្ពៅ២២សំណាក ត្រសក់៣៥សំណាក និងគ្រប់ចំនួន៩សំណាក និងបន្តការអភិរក្សពូជដំណាំនៅក្នុងវិទ្យាស្ថានចំនួន ៣៩ប្រភេទ រួមមាន ស្រូវចំនួន ៦ ៧៧៦បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន ៣៨ប្រភេទ សរុបចំនួន ២ ៦០១បញ្ជីក/សំណាក សរុបទាំងអស់មានចំនួន ៩ ៣៧៧បញ្ជីក/សំណាក

- ធ្វើពិសោធន៍ចំនួន ៧១ប្រភេទ នៅ២៧៤កន្លែង ព្រមទាំងបានធ្វើការអង្កេតស្រាវជ្រាវចំនួន ៣លើក

- ផ្តល់បទសម្ភាសន៍ចំនួន ១លើកស្តីពីការងារស្រាវជ្រាវរបស់វិទ្យាស្ថានដល់ក្រុមការងារគម្រោង CAVAC នៅវិទ្យាស្ថាន

- រៀបចំបើកវគ្គបណ្តុះបណ្តាលកសិករ ជួបប្រជុំជាមួយកសិករ និងធ្វើទិវាស្រែបង្ហាញចំនួន ៤៤លើក មានកសិករចូលរួមសរុបចំនួន ១ ៣០៨នាក់ (នារី៦២៤នាក់ ស្មើនឹង៤៨%)

- មានអ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន ៣៤៦ ៥៩៥នាក់ ដោយគិតជាមធ្យមមានប្រមាណ១ ២៨៣នាក់/ថ្ងៃ។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២២សរុបចំនួន ៣ ១៤៤នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺៈ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- ចុះអនុស្សរណៈយោគយល់រវាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងក្រុមហ៊ុនដាវ៉ាន់ ភីអិលស៊ី ក្នុងការអនុវត្ត

គម្រោងស្តីពីការប្រើប្រាស់ធនធាន ដើម្បីលើកកម្ពស់សុវត្ថិភាពចំណីអាហារ និងខ្សែច្រវាក់តម្លៃកសិកម្មនៅកម្ពុជា

- រៀបចំវគ្គបណ្តុះបណ្តាលអំពីការអភិវឌ្ឍន៍ផលិតផលពីផ្លែស្វាយចន្ទី ដល់អ្នកកែច្នៃស្វាយចន្ទី និងម្ចាស់ចម្ការស្វាយចន្ទី ដែលគាំទ្រដោយគម្រោងកែលម្អអប់រំឧត្តមសិក្សា (HEIP)

- អ្នកជំនាញចំណីត្រី ២រូប និងប្រព័ន្ធទឹកវិល ១រូបនៃ Worldfish Malaysia មកដំឡើងប្រព័ន្ធពិសោធន៍លើចំណីផ្សំក្នុងការចិញ្ចឹមត្រីអណ្តែងទន់ និងទស្សនកិច្ចសិក្សាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខណ្ឌរដ្ឋបាលជលផល ផ្សារត្រី ទំបន់វារីអគ្គិសនីសេសានក្រោម២ មជ្ឈមណ្ឌលវារីវប្បកម្មទើបសង់ថ្មី និងទីជម្រកត្រីសំខាន់ៗ។

## ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២២ សរុបចំនួន ១ ២៦២នាក់ (ស្រី៤៩៦នាក់) លើជំនាញ៖ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និងភាសាអង់គ្លេស

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូ ដើម្បីជាប្រយោជន៍សម្រាប់ការសិក្សាស្រាវជ្រាវរបស់និស្សិត និងមន្ត្រីដោយការសិក្សាស្រាវជ្រាវផ្តោតលើ៖ ត្រី បង្កង បង្គា មាន់ ទា ពពែ ក្របី គោទឹកដោះ បន្លែ ផ្កា ឫស្សី ស្រូវ ចេក ស្វាយចន្ទី កាកាវ វ៉ានីឡា ស្ពៅ អាហារ ថ្នាំសត្វល្អិត និងដី

- សហប្រតិបត្តិការសំខាន់ៗរួមមានការបណ្តុះជាលិការុក្ខជាតិ អាក្វាពោនិក (ប្រព័ន្ធវារីវប្បកម្ម) ការកែច្នៃស្វាយចន្ទី ការផលិតម្សៅឫស្សី ការចិញ្ចឹមគោទឹកដោះ ការពិសោធដំណាំជប៉ុន និងការសរសេរសៀវភៅសម្រាប់ការបណ្តុះបណ្តាលរបស់វិទ្យាស្ថាន

- រៀបចំសិក្ខាសាលាដើម្បីកែលម្អប្រព័ន្ធអប់រំឧត្តមសិក្សា និងបានបន្តការរៀបចំកែ លម្អប្រព័ន្ធគុណភាពអប់រំឧត្តមសិក្សា។

## ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២២ សរុបចំនួន ៥៩៤នាក់ (ស្រី២០៩នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ពិសោធន៍លើការចម្រាញ់ប្រេងរុក្ខជាតិដូចជា ស្លឹកគ្រៃ ស្លឹកក្រូចសើច និងម្រេច
- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់
- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា
- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្ម កំពង់ចាម
- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប
- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

## ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- តាមដាន ស្រង់ វិភាគទិន្នន័យចម្ការពិសោធន៍ទាំងនៅក្នុងស្ថានីយ ទាំងនៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូសរុបចំនួន ៦២ពិសោធន៍

- ថែទាំកូនកៅស៊ូ Tissue Culture Plant ចំនួន ២៥០០កូន ដែលទទួលមកពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូចិន (RRI-CATAS)

- យកសំណាក និងវិភាគសរីរទឹកជ័រចម្ការកៅស៊ូក្នុងស្ថានីយពិសោធន៍បានចំនួន ២០៧សំណាក

- ចុះត្រួតពិនិត្យ និងតាមដានវឌ្ឍនភាពការងារពាក់ព័ន្ធផលិតកម្មកៅស៊ូក្នុងខេត្តកំពង់ធំ សៀមរាប ឧត្តរមានជ័យ ពោធិ៍សាត់ និងខេត្តកោះកុង

- អនុវត្តការងារថែទាំកូនកៅស៊ូគ្រប់ចម្ការពិសោធន៍
- បន្តអនុវត្តការងាររៀបចំថ្នាលបណ្តុះកូនកៅស៊ូសម្រាប់ឆ្នាំ២០២២-២០២៣
- អនុវត្តការងារមន្ទីរពិសោធន៍យថាប្រភេទកៅស៊ូតាមប្រព័ន្ធគ្រប់គ្រងគុណភាព ISO/IEC 17025: 2017
- ធ្វើតេស្តកៅស៊ូសន្លឹក (RSS) ចំនួន ៦សំណាក ដើម្បីពិនិត្យគុណភាពនៃការកែច្នៃតាមស្តង់ដា CSR។

## III- សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបានចំនួន ២ ៦៩២ ០៩២ហ.ត ស្មើនឹង១០២,៧៧% នៃផែនការចំនួន ២ ៦១៩ ៥០០ហ.ត និងការប្រមូលផលស្រូវស្រាលសម្រេចចំនួន ៥៤១ ៧៨៨ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ២ ១៦៣ ២០៨តោន និងទទួលបានទិន្នផលគិតជាមធ្យម ៣,៩៩៣តោន/ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសមាសភាពចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈឺក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១- ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្ម
- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម
- បន្តអង្កេតទូទៅអំពីស្ថានភាពដីគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យដីកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

### ២- ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើ

អនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- បន្តពង្រឹង និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វដល់កសិករ

- ត្រៀមលក្ខណៈចុះអនុវត្តវិធានការបសុព្យាបាលកន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ជំងឺដុំពកស្បែកគោ ក្របី (LSD) និងជំងឺឆ្លងសត្វផ្សេងៗ

- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បន្តរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

### ៣- ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹង លេខ១៣៤៨ សជណ.កច ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីរំលោភយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

### ៤- ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការសហគមន៍នេសាទគ្មានបទល្មើសជលផល។

### ៥- ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ប្រើប្រាស់

ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ៕

ថ្ងៃ ព្រហស្បតិ៍ ១០ រោច ខែ អស្សុជ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០២២

**ជ.រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**រដ្ឋលេខាធិការប្រចាំការ**

នុត_ចំនួនសុខា